**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jan-2013, 10:41
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់ អៀង សារី សុំដាក់ចំណាត់ថ្នាក់ជាថ្មីនៃឯកសារ E238/4 ជាឯកសារសាធារណៈ

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្ដម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូ ឧត្ដរា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង ធូ មណី

ចៅក្រមបំរុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន២១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ(“វិធានផ្ទៃក្នុង”) និងមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក (“មាត្រា៣.១៤ នៃសេចក្តីណែនាំអនុវត្ត”) តទៅនេះសូមស្នើអង្គជំនុំជម្រះសាលាដំបូងដាក់ចំណាត់ថ្នាក់ជាថ្មីនៃឯកសារ E238/4, របាយការណ៍ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់សាស្ត្រាចារ្យ Campbell អំពីការពិនិត្យរបស់គាត់លើលោក អៀង សារី, ពី “សម្ងាត់បំផុត” ទៅជា “សាធារណៈ”។ សំណើនេះត្រូវធ្វើឡើងជាចាំបាច់ ពិព្រោះឯកសារ E238/4 ពុំមានព័ត៌មាន “សម្ងាត់បំផុត” ដែលរារាំងវាមិនឲ្យដាក់ចំណាត់ថ្នាក់ជាសាធារណៈបាននោះទេ៖

1. លោក អៀង សារី បានយល់ព្រមឲ្យរបាយការណ៍វេជ្ជសាស្ត្ររបស់គាត់ដាក់ជាសារធារណៈ[1]។
2. ខ្លឹមសារនៃឯកសារ E238/4 ត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅតុលាការ[2]។
3. វិធាន២១(១) តម្រូវថាសេចក្តីអនុវត្តណែនាំអនុវត្តទាំងអស់ ត្រូវតែបកស្រាយ “ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនិតីវិធីប្រកបដោយតម្លាភាព” ។
4. មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្ត ចែងថាតម្រូវតាមផលប្រយោជន៍យុត្តិធម៌អង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចដាក់ចំណាត់ថ្នាក់ឯកសារជាថ្មីក្នុងសំណុំរឿង ។

ការដាក់ចំណាត់ថ្នាក់ជាថ្មីនៃឯកសារ E238/4 ជាសាធារណៈ នឹងលើកកម្ពស់តម្លាភាព និងជាផលប្រយោជន៍យុត្តិធម៌ ។

**អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ** មេធាវីការពារក្តីស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង**ដាក់ចំណាត់ថ្នាក់ជាថ្មី**នៃ E238/4 ជាសាធារណៈ ។

សូមលោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយកសំណើនេះដោយគោរព ។

---

[1] សូមមើលទម្រង់យល់ព្រមរបស់លោក អៀង សារី ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ E1/142.2 ។

[2] សូមមើលប្រតិចារិតចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ E1/142.1 ។ សូមមើលប្រតិចារិតចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ E1/143.1 ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៩** ខែ **មករា** ឆ្នាំ **២០១៣**

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |

សហមេធាវីរបស់លោក **អៀង សារី**